សលាកប័ត្រព័ត៌មាន ៖ ការធ្វើបត្យាប័ននៅប្រទេសកម្ពុជា

**សេចក្តីសង្ខេប** ៖ នីតិវិធីធ្វើបត្យាប័ននៅប្រទេសកម្ពុជា ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ("ក្រម") និងសន្ធិសញ្ញាធ្វើបត្យាប័នទ្វេភាគី ។ ជាងនេះទៅទៀត មាត្រដ្ឋានអន្តរជាតិផ្តល់គោលការណ៍ណែនាំ ដែលមានសារសំខាន់ ស្តីពីនីតិវិធីធ្វើបត្យាប័នសមស្រប ។ ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍ថ្មីៗបានបង្ហាញថា ការអនុវត្តន៍ការធ្វើបត្យាប័ននៅប្រទេសកម្ពុជា គួរតែត្រូវបានត្រួតពិនិត្យឡើងវិញ ដើម្បីរួមបញ្ចូលសិទ្ធិមនុស្ស និងដើម្បីធានាថាការធ្វើបត្យាប័នត្រូវបានអនុវត្តដោយគ្មានការបង្អាក់ ។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ ផ្តល់សេចក្តីសង្ខេបអំពីស្ថានភាពនៃការអនុវត្តន៍ការអធ្វើបត្យាប័ននាពេលបច្ចុប្បន្ន នៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ។ ច្បាប់ស្តីពីការធ្វើបត្យាប័នរបស់កម្ពុជា នៅមិនទាន់មានលក្ខណៈជាក់លាក់នៅត្រង់ចំនុចមួយចំនួន និងមានភាពខ្វះចន្លោះនៅឡើយ ដែលជាពិសេសពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស និងដោយភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុវត្តន៍ច្បាប់ ។ សលាកប័ត្រនេះតាក់តែងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា ។

## ការធ្វើបត្យាប័ន

ការធ្វើបត្យាប័នអាចត្រូវបានកំណត់និយមន័យថាជា ការប្រគល់ខ្លួនបុគ្គលម្នាក់ដោយរដ្ឋ ("រដ្ឋដែលត្រូវបានស្នើសុំ") ទៅឲ្យអាជ្ញាធររបស់រដ្ឋមួយទៀត ("រដ្ឋដែលបានធ្វើការស្នើសុំ") ក្នុងគោលបំណងផ្តន្ទាទោសព្រហ្មទណ្ឌ ឬការអនុវត្តន៍ការកាត់ទោស ។ ទោះបីជាការធ្វើបត្យាប័នមិនមែនជាទស្សនៈថ្មីក៏ដោយ សកលភាវូបនីយកម្ម និងការធ្វើដំណើររបស់ប្រជាជន ឆ្លងកាត់ព្រំដែន និងយុត្តាធិការរដ្ឋ បានធ្វើឲ្យគោលការណ៍ណែនាំជាក់លាក់សម្រាប់ការធ្វើបត្យាប័ន ឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសក្លាយទៅជាភាពចាំបាច់ ។

## គោលការណ៍ណែនាំអន្តរជាតិស្តីពីការធ្វើបត្យាប័ន

ការធ្វើបត្យាប័នអន្តររដ្ឋ តាមទំនៀមទំលាប់ត្រូវបានគ្រប់គ្រងដោយសន្ធិសញ្ញាទ្វេភាគី ដែលបានបញ្ជាក់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការធ្វើបត្យាប័នឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់ នៅក្នុងប្រទេសពីរ ។ សន្ធិសញ្ញាក្នុងតំបន់ ដូចជាអនុសញ្ញាអន្តរអាមេរិកកាំងស្តីពីការធ្វើបត្យាប័ន ក៏ត្រូវបានអនុម័តផងដែរសម្រាប់បម្រើគោលបំណងនៃការធ្វើបត្យាប័ន ទោះបីជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ("អាស៊ាន") មិនទាន់បានបង្កើតសន្ធិសញ្ញាបែបនេះក៏ដោយ ។

ទោះបីជាច្បាប់អន្តរជាតិ មិនបានផ្តល់កាតព្វកិច្ចឲ្យរដ្ឋធ្វើបត្យាប័នក៏ដោយ សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ ស្តីពីការធ្វើបត្យាប័ន ("សន្ធិសញ្ញាគំរូរបស់ អ.ស.ប") បានចែងអំពីគំរូសម្រាប់ច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការធ្វើបត្យាប័ន ព្រមទាំងមានបំណងចែងអំពីប្រទេសដែលមានមូលដ្ឋានបែបនេះ ដើម្បីធានាថាដំណើរការនៃការធ្វើបត្យាប័ន ឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ។ មាត្រា៣ ចែងថាការធ្វើបត្យាប័នមិនត្រូវបានអនុញ្ញាត ប្រសិនបើបុគ្គលដែលត្រូវបានស្នើសុំឲ្យធ្វើបត្យាប័ន អាចពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ហើយការធ្វើបត្យាប័នអាចនឹងត្រូវបានបដិសេធ ប្រសិនបើរដ្ឋដែលត្រូវបានស្នើសុំ ចាត់ទុកថាបទល្មើសដែលត្រូវស្នើឲ្យមានការធ្វើបត្យាប័ន មានពាក់ព័ន្ធនឹងនយោបាយ ។ រដ្ឋដែលត្រូវបានស្នើឲ្យធ្វើបត្យាប័ន ត្រូវបដិសេធសំណើសុំធ្វើបត្យាន ប្រសិនបើរដ្ឋដែលធ្វើការស្នើសុំមានការកាត់ទោសប្រហារជីវិតចំពោះបទល្មើស លុះត្រាតែមានការធានាថានឹងមិនមានការអនុវត្តការកាត់ទោសប្រហារជីវិត ។ ក្នុងករណីបែបនេះ សេចក្តីសម្រេចថាមិនធ្វើបត្យាប័នមានលក្ខណៈស្របច្បាប់ ។

## ការធ្វើបត្យាប័ន និងប្រទេសកម្ពុជា

ការធ្វើបត្យាប័នប្រជាពលរដ្ឋខ្មែរ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដែលបានចែងក្នុងមាត្រា៣៣ថា "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសនណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។" ជាងនេះទៅទៀត រដ្ឋធម្មនុញ្ញបានចែងថា សន្ធិសញ្ញាអន្តរជាតិដែលមានកម្មវិធីជាភាគី ត្រូវដាក់បញ្ចូលក្នុងច្បាប់ជាតិ ។ កម្ពុជាគឺជាប្រទេសដែលបានចុះហត្ថលេខាលើសន្ធិសញ្ញាបែបនេះជាច្រើន ដែលមានបំណងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលហេតុនេះហើយ កម្ពុជាត្រូវអនុវត្តតាមសន្ធិសញ្ញានេះ នៅពេលធ្វើសេចក្តីសម្រេចធ្វើបត្យាប័ន ។

ការធ្វើបត្យាប័នត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ("ក្រម") ។ ក្រមនេះអាចយកមកអនុវត្តក្នុងការស្នើសុំការធ្វើបត្យាប័ន នៅពេលអវត្តមាននៃសន្ធិសញ្ញានៃការធ្វើបត្យាប័ន រវាងប្រទេសកម្ពុជា និងរដ្ឋដែលស្នើសុំការធ្វើបត្យាប័ន ។ ក្រមនេះបានរៀបរាប់យ៉ាងលម្អិតអំពីដែនកំណត់នៃការធ្វើបត្យាប័ន និងមូលហេតុដែលការធ្វើបត្យាប័នអាចត្រូវបានបដិសេធ ព្រមទាំងបានរួមបញ្ចូលបទបញ្ញាដែលមានការទទួលស្គាល់ ក្នុងសន្ធិសញ្ញាអន្តរជាតិ ។ ក្រមនេះក៏បានរៀបរាប់ អំពីនីតិវិធីនៃការស្នើសុំការធ្វើបត្យាប័នផងដែរ ។ ទោះបីជាប្រទេសកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាធ្វើបត្យាប័ន ជាមួយប្រទេសតែបី (ថៃ ចិន និងឡាវ) ក៏ដោយ បទប្បញ្ញត្តិនៃការធ្វើបត្យាប័ន ដែលមាននៅក្នុងក្រមនេះ បានផ្តល់គោលការណ៍ណែនាំដែលមានសារសំខាន់បំផុត អំពីនីតិវិធីធ្វើបត្យាប័ននៅប្រទេសកម្ពុជា ។

## បញ្ហានៃការធ្វើបត្យាប័ននៅប្រទេសកម្ពុជា

មានភាពមិនស៊ីសង្វាក់គ្នាមួយចំនួនរវាងសន្ធិសញ្ញាគំរូរបស់ អ.ស.ប និងបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការធ្វើបត្យាប័នរបស់កម្ពុជា ដូចជារយៈពេលនៃការឃុំខ្លួនជនសង្ស័យដែលត្រូវបានអនុញ្ញាត នៅពេលពិចារណាលើសំណើធ្វើបត្យាប័ន ៖ ខណៈពេលដែលសន្ធិសញ្ញាគំរូរបស់ អ.ស.ប អនុញ្ញាតឲ្យមានរយៈពេលត្រឹម៤០ថ្ងៃ ក្រមនេះអនុញ្ញាតឲ្យមានរយៈពេល៦០ថ្ងៃ ។ ជាងនេះទៅទៀត ក្រមនេះមិនបានចែងអំពីបញ្ហាសិទ្ធិមនុស្សសំខាន់ៗឡើយ ។ ដោយខុសប្លែកពីសន្ធិសញ្ញាគំរូរបស់ អ.ស.ប ក្រមនេះមិនបានចែងថា ការដាក់ទណ្ឌកម្មគឺជាមូលហេតុចាំបាច់ និង ឬមានលក្ខណៈខុសប្លែក ដើម្បីបដិសេធការស្នើសុំការធ្វើបត្យាប័នឡើយ ។ ស្រដៀងគ្នានេះដែរ ក្រមនេះមិនបានចែងឲ្យបានច្បាស់ថា ការធ្វើបត្យាប័នត្រូវបានបដិសេធ នៅពេលដែលបុគ្គលដែលគេធ្វើបត្យាប័ន ត្រូវកាត់ទោសប្រហារជីវិតនៅក្នុងប្រទេសដែលស្នើសុំការធ្វើបត្យាប័នឡើយ ។ ដោយហេតុថាក្រមនេះចូលជាធរមានចំពោះការស្នើសុំការធ្វើបត្យាប័ន នៅពេលមិនមានសន្ធិសញ្ញាដែលពាក់ព័ន្ធ និងទោះបីជាប្រទេសកម្ពុជាមានសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងធ្វើបត្យាប័នតិចតួចក៏ដោយ ភាពខ្វះចន្លោះនេះគឺជាបញ្ហាដែលគួរឲ្យបារម្ភ ។

ករណីទើបនឹងកើតឡើងថ្មីៗរបស់អ្នកជំនួញជនជាតិរ៉ូស្ស៊ី អាឡិចហ្សេនឌឺ ត្រូហ្វីមូវ ប្រធានក្រុមវិនិយោគដែលដំណើរការនៅប្រទេសកម្ពុជា គឺជាឧទាហរណ៍នៃភាពខ្វះចន្លោះ ក្នុងក្របខណ្ឌច្បាប់នៃការធ្វើបត្យាប័ន នៅប្រទេសកម្ពុជា ។ ត្រូហ្វីមូវ ត្រូវបានលើកលែងទោសនៅខែធ្នូ ឆ្នាំ២០១១ ទោះបីជាមានការកាត់ឲ្យជាប់ទោសរយៈពេលបួនឆ្នាំ ជាជាងប្រាំបីឆ្នាំ ដោយការបំពានលើកុមារមិនទាន់ពេញវ័យ និងទោះបីជាមានការស្នើសុំពីប្រទេសរ៉ូស្ស៊ី ឲ្យធ្វើបត្យាប័នគាត់ ពីបទឧក្រិដ្ឋប្រហាក់ប្រហែលគ្នាដែលគាត់បានប្រព្រឹត្តនៅទីនោះ ។ នៅពេលដែលគាត់ត្រូវបានចាប់ខ្លួនម្តងទៀតនៅប្រទេសកម្ពុជានៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ ជាថ្មីម្តងទៀត រដ្ឋាភិបាលកម្ពុជាជ្រើសរើសមិនពិចារណាចំពោះសំណើធ្វើបត្យាប័ន ហើយបន្ទាប់មក បែរជាបញ្ជូនគាត់ទៅប្រទេសកូរ៉េខាងត្បូងយ៉ាងឆាប់រហ័ស ។ ការបដិសេធជាញឹកញាប់ របស់រាជរដ្ឋាភិបាលកម្ពុជា ("រ.ដ.ក") ក្នុងការធ្វើបត្យាប័ន ត្រូហ្វីមូវ បង្ហាញអំពីបំណងរបស់ រ.ដ.ក ដើម្បីចៀសផុតពីច្បាប់ស្តីពីការធ្វើបត្យាប័ន ។

## ការសន្និដ្ឋាន ឬអនុសាសន៍

ទោះបីជានីតិវិធីធ្វើបត្យាប័ន ត្រូវបានបញ្ជាក់នៅក្នុងក្រមនេះក៏ដោយ កំណែទម្រង់ក្របខណ្ឌច្បាប់របស់កម្ពុជាឲ្យបានឆាប់រហ័សពាក់ព័ន្ធនឹងការធ្វើបត្យាប័ន មានលក្ខណៈចាំបាច់ ។ ជាដំបូង ក្រមនេះគួរត្រូវបានត្រួតពិនិត្យឡើងវិញ ឲ្យសមស្របទៅតាមសន្ធិសញ្ញាគំរូរបស់ អ.ស.ប ជាពិសេសដោយការដាក់បញ្ចូលមាត្រា៣ និង៤ ។ រ.ដ.ក គួរចាប់ផ្តើមដំណើរការ ដែលណែនាំដោយសន្ធិសញ្ញាគំរូរបស់ អ.ស.ប និង មាត្រដ្ឋានសិទ្ធិមនុស្ស អំពីការបង្កើតកិច្ចព្រមសន្ធិសញ្ញាទ្វេភាគី ជាមួយនឹងប្រទេសកាន់តែច្រើន ។ ជាចុងក្រោយ រ.ដ.ក គួរចាត់វិធានការជាបន្ទាន់ ដើម្បីធានាថា ក្រមខណ្ឌដែលមាននៅពេលបច្ចុប្បន្នត្រូវបានអនុវត្ត ហើយវិធីសាស្រ្តផ្សេងទៀត ដូចជាការបណ្តេញចេញពីប្រទេស មិនត្រូវបានប្រើប្រាស់ក្នុងករណីត្រូវធ្វើបត្យាប័នឡើយ ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទ (+៨៥៥ (0) ១២ ៤០ ៤០ ៥១) ឬអ៊ីម៉ែល ouvirak@cchrcambodia.org ឬ លោក ចន ខហ្វឡែន (+៨៥៥ (0) ៨៩ ៥៨ ៣៥ ៩០) ឬអ៊ីម៉ែល johncoughlan@cchrcambodia.org ។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

cc BY NC SA